JICA Cambodia Office - JICA カンボジア事務所

September 18 at 5:46 PM ·

【ព្រឹត្តិការណ៍សំខាន់សម្រាប់គិលានុបដ្ឋាកកម្ពុជា៖ ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) នៅថ្នាក់ខេត្ត លើកដំបូងត្រូវបានចាប់ផ្តើម!/ A Milestone for Cambodia's Nurses: First Provincial In-Service Training (INSET) Launched! 】

-----------------------------

បាត់ដំបង៖ នៅថ្ងៃទី១០-១១ ខែកញ្ញា ឆ្នាំ២០២៥ នៅប្រទេសកម្ពុជាបានចាប់ផ្តើមបើកវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) ជាលើកដំបូងសម្រាប់គិលានុបដ្ឋាកក្នុងខេត្តបាត់ដំបងដោយផ្អែកតាមគោលការណ៍ណែនាំថ្នាក់ជាតិ។ នេះគឺជាជំហ៊ានសំខាន់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីជាគិលានុបដ្ឋាកក្នុងការថែទាំជំងឺនៅកម្ពុជា។ ក្នុងរយៈពេល៦ខែខាងមុខមានវគ្គបណ្តុះ
បណ្តាលចំនួន ២២វគ្គ នឹងត្រូវបានរៀបចំឡើងនៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម។
វគ្គបណ្តុះបណ្តាលស្តីពី សីលធម៌នៃការថែទាំ (គិលានុបដ្ឋាក ៣៥នាក់) និងវគ្គ ការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ (គិលានុបដ្ឋាក ៣០នាក់) ត្រូវបានធ្វើឡើងដំបូងគេ។ ឯកឧត្តមវេជ្ជបណ្ឌិត វឿង ប៊ុនរេត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានចូលរួមវគ្គបើកវគ្គបណ្តុះបណ្តាល និងលើកទឹកចិត្តដល់សិក្ខាកាមឱ្យយកចំណេះដឹងដែលទទួលបានពីការសិក្សាទៅអនុវត្តជាក់ស្តែង ដើម្បីរួមចំណែកលើកកម្ពស់គុណភាពនៃការថែទាំឱ្យមានប្រសិទ្ធភាពខ្ពស់។
ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) លើកនេះ មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តជាអ្នករៀបចំដោយផ្ទាល់ ដោយមានការដឹកនាំពីគ្រូបង្គោលក្នុងខេត្តដែលបានបញ្ចប់ការសិក្សារួច និងក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្នុងគោលបំណងបង្កើតប្រព័ន្ធដែលអាចរៀបចំ និងគ្រប់គ្រងការបណ្តុះបណ្តាលដោយខ្លួនឯងបន្ទាប់ពីគម្រោងបានបញ្ចប់។ ទិសដៅរបស់គម្រោងនេះមានគោលបំណងក្នុងការសម្រេចឱ្យបានជាង ៧០% នៃគិលានុបដ្ឋាកនៅក្នុងខេត្តសាកល្បង ដើម្បីបង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់គិលានុបដ្ឋាកក្នុងការផ្តល់សេវាថែទាំឱ្យកាន់តែប្រសើរឡើងនៅទូទាំងប្រទេសកម្ពុជា៕
គេហទំព័រគម្រោង៖

The Project for Strengthening In-service Training System in Cambodia

https://www.jica.go.jp/oda/project/2004000/index.html…

Battambang, On September 10th –11th, 2025, Cambodia kicked off its first-ever provincial In-Service Training (INSET) for nurses in Battambang under the National Guideline. This marks a major milestone in strengthening the capacity of Cambodia's nursing workforce. Over the next six months, 22 sessions will be held in Battambang and Kampong Cham.

The opening featured Nursing Ethics (35 nurses) and Nursing Management and Leadership (30 nurses). H.E. Dr. VOEURNG Bunreth, Director of Battambang Provincial Health Department, joined the sessions and encouraged participants to put their learning into practice and contribute to improving the quality of nursing care.

INSET introduces a self-sustained provincial model, led by certified local trainers and Provincial Training Management Teams with the aim of building a system that can sustain training beyond the project's completion. The Project aims to reach over 70% of nurses in the pilot provinces, building a strong foundation for better nursing care across Cambodia.

Project Website:

The Project for Strengthening In-service Training System in Cambodia

https://www.jica.go.jp/oda/project/2004000/index.html…









